**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១៥០ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ សន/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណូមពរការងារចាំបាច់

**ស ម្រេ ច**

**ប្រការ ១.-**

បង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **មៀច សុផាន់ណា** | អនុរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | **ប្រធាន** |
| ២-ឯកឧត្តម | **ប៉ុក ម៉ាន់នី** | អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ | **អនុប្រធាន** |
| ៣-ឯកឧត្តម នាយឧត្តមសេនីយ៍ | **ភខ សុខន** | អគ្គស្នងការរងនគរបាលជាតិ | **សមាជិក** |
| ៤-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សរ សិទ្ធិ** | ទីប្រឹក្សាក្រសួងមហាផ្ទៃ | **សមាជិកអចិន្ត្រៃយ៍** |



www.pheakdeylaw.com

| | | |
|---|---|---|
| ៥-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ជា សុមេធី** | អគ្គស្នងការរងនគរបាលជាតិ និងជាប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច សមាជិក |
| ៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ស៊ិន សុផានី** | មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស និងជាស្នងការ នៃស្នងការដ្ឋានស្រាវជ្រាវនិងយុត្តិធម៌ សមាជិក |
| ៧-ឯកឧត្តម | **ឯមយិន ធរៈ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា សមាជិក |
| ៨-ឯកឧត្តម | **គឹម មាសសុខសីហា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានកាំកុងត្រូល សមាជិក |
| ៩-លោកឱសថការី | **ហុត សេនថុន** | អនុប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសម្អាង ក្រសួងសុខាភិបាល សមាជិក |
| ១០-លោកឧត្តមសេនីយ៍ត្រី | **ឡុង ស្រេង** | អនុប្រធាននាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច សមាជិក |
| ១១-លោកវរសេនីយ៍ឯក | **សួន ណារ៉ា** | នាយការិយាល័យការពារតម្លៃ បរិមាណ និងគុណភាព នៃនាយកដ្ឋាននគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច សមាជិក |

**ប្រការ ២.-**

គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម មានវិសាលភាពអនុវត្តទូទាំងព្រះរាជាណាចក្រកម្ពុជា មានភារកិច្ចដូចតទៅ ៖

- សហការជាមួយស្ថាប័នជាតិនិងអន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម
- ស្រាវជ្រាវ ស៊ើបអង្កេតរកប្រភពនៃផលិតផលក្លែងក្លាយ ការនាំចូល ការផលិត ការស្តុកទុក និងការចែកចាយ
- អប់រំផ្សព្វផ្សាយដល់សាធារណជនអំពីផលប៉ះពាល់ នៃការប្រើប្រាស់ផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម
- ចាត់វិធានការបង្ក្រាបរាល់ផលិតផលក្លែងក្លាយ ដែលចរាចរនៅទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា ដោយការឃាត់ទុក ដើម្បីរៀបចំសំណុំរឿងបញ្ជូនទៅតុលាការ ធ្វើការវិនិច្ឆ័យទោសតាមច្បាប់
- បណ្តុះបណ្តាល បង្កើនការយល់ដឹង និងពង្រឹងសមត្ថភាពដល់មន្ត្រីអនុវត្តន៍ច្បាប់ ព្រមទាំងវិស័យឯកជនពាក់ព័ន្ធនានា
- ក្នុងដំណាក់កាលបំពេញភារកិច្ចជាក់ស្តែង គណៈកម្មាធិការត្រូវរាយការណ៍ជាប្រចាំពីការអនុវត្តការងាររបស់ខ្លួនជូន ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**ប្រការ ៣.-**

- គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃលើរាល់លិខិតស្នាម
- គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម ត្រូវមានថវិកាសម្រាប់ដំណើរការរដ្ឋបាល ។ ថវិកានេះត្រូវស្ថិតនៅក្នុងកញ្ចប់ថវិកាប្រចាំឆ្នាំរបស់ ក្រសួងមហាផ្ទៃ ។

www.pheakdeylaw.com

**ប្រការ ៤.~**

- គណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម ត្រូវមានលេខាធិការដ្ឋានមួយ
- លេខាធិការដ្ឋាននេះត្រូវដឹកនាំដោយប្រធានមួយរូប និងមានជំនួយការមួយចំនួនតាមការចាំបាច់ ។ មន្ត្រីលេខាធិការដ្ឋាននេះ ជាមន្ត្រីស្ថិតក្នុងក្របខណ្ឌក្រសួងមហាផ្ទៃ និងជាមន្ត្រីស្ថិតក្នុងក្របខណ្ឌ ក្រសួង-ស្ថាប័ននានា នៃរាជរដ្ឋាភិបាល ដែលទទួលការតែងតាំងក្នុងគណៈកម្មាធិការនេះ ។ ការតែងតាំង ការរៀបចំ និងការប្រព្រឹត្តទៅ នៃលេខាធិការដ្ឋាននេះ ត្រូវធ្វើឡើងដោយប្រកាស ក្រសួងមហាផ្ទៃ ។

**ប្រការ ៥.~**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

*រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៤*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

*អន្លែងទទួល ៖*
*-ក្រសួងព្រះបរមរាជវាំង*
*-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
*-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
*-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
*-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
*-ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ដូចប្រការ៥*
*-រាជកិច្ច*
*-ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com